# ច្បាប់
# ស្តីពី
# ការរៀបចំអង្គការតុលាការ និងអយ្យការ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។ អំណាចនេះត្រូវប្រគល់ឱ្យ តុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលត្រូវរៀបចំបង្កើតឡើងដោយច្បាប់នេះ ។

**មាត្រា ២.-**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ដោយតុលាការដែលមានលំដាប់ដូចតទៅ :

- តុលាការកំពូល
- សាលាឧទ្ធរណ៍
- សាលាដំបូង ។

តុលាការយោធាជាតុលាការដោយឡែកដែលមានថ្នាក់ស្មើនឹងសាលាដំបូង ។

ក្រៅពីតុលាការដែលបានរៀបរាប់ខាងលើនេះ តុលាការពិសេស ឬតុលាការវិសាមញ្ញអាចត្រូវបានបង្កើតឡើងដោយច្បាប់ដោយឡែក យោងតាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ។

នៅក្នុងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ការបង្កើត ការលុបចោល និងការកែប្រែសភាឯកទេស ត្រូវកំណត់ដោយច្បាប់ ។

ប្រធាននៃតុលាការនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់ លើប្រធានសភាទាំងអស់នៃតុលាការនោះ ។ ប្រធានសភានីមួយៗមានអំណាចឋានានុក្រម

ផ្នែករដ្ឋបាល ដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានតុលាការពុំអាចធ្វើជាប្រធានសភាណាមួយបានឡើយ ។

ប្រធានសភានីមួយៗ អាចធ្វើជាប្រធានសភាបានតែមួយគត់ ។

**មាត្រា ៣.-**

នីតិវិធីនៅចំពោះមុខតុលាការ ត្រូវប្រព្រឹត្តទៅដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ឬនីតិវិធីរដ្ឋប្បវេណី លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ ។

**មាត្រា ៤.-**

សវនាការត្រូវធ្វើជាសាធារណៈ លើកលែងតែសាធារណភាពនេះអាចបង្កឱ្យប៉ះពាល់ជាអាទិ៍ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬទំនៀមទម្លាប់ល្អប្រពៃ ឬ ករណីដែលជនរងគ្រោះ ឬសិទ្ធិវិន្តរបស់ជននេះស្នើសុំឱ្យជំនុំជម្រះជាអសាធារណៈ ។ ក្នុងករណីចុងក្រោយនេះ តុលាការដែលបានទទួលបណ្តឹងត្រូវប្រកាសអំពីបញ្ហាអសាធារណភាពនេះនៅមុនពេលសវនាការ តាមដីកាសម្រេចមួយដាច់ដោយឡែក ដែលមានសំអាងហេតុ ។

នៅគ្រប់ករណីទាំងអស់ សេចក្តីសម្រេចរបស់តុលាការត្រូវប្រកាសជាសាធារណៈ ។

**មាត្រា ៥.-**

មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

មានតែសាលាជម្រះក្តីដែលមានចែងដោយច្បាប់នេះប៉ុណ្ណោះ ទើបអាចប្រកាសសេចក្តីសម្រេចតុលាការបាន ។ សាលដីកា សាលក្រម និងដីកាសម្រេច ត្រូវមានសំអាងហេតុ និងសំអាងច្បាប់ ។

ជនណាក៏ដោយ មិនអាចត្រូវបានតុលាការជំនុំជម្រះដោយមិនបានបង្ហាញមធ្យោបាយការពារខ្លួនឡើយ ។

**មាត្រា ៦.-**

នៅគ្រប់តុលាការ មានការិយាល័យក្រឡាបញ្ជីដែលមានសមាសភាព នាយកក្រឡាបញ្ជី នាយករងក្រឡាបញ្ជី ក្រឡាបញ្ជី និងមន្ត្រីជំនួយការ ។ ក្រឡាបញ្ជីជួយចៅក្រម នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ ។ នៅគ្រប់ករណីទាំងអស់ ក្រឡាបញ្ជីមិនអាចសួរចម្លើយគូភាគី ឬតាក់តែងសេចក្តីសម្រេចជំនួសចៅក្រមបានឡើយ ។

តួនាទី និងមុខងារ របស់ក្រឡាបញ្ជី ត្រូវកំណត់នៅក្នុងលក្ខន្តិកៈក្រឡាបញ្ជី ។

**មាត្រា ៧.-**

នៅក្នុងរឿងក្តីមួយ កាលបើរាល់ផ្លូវប្តឹងតវ៉ាត្រូវបានប្រើប្រាស់អស់ហើយ ឬកាលបើរយៈពេលប្តឹងតវ៉ា ហួសពេលកំណត់អស់ហើយនោះ សាលក្រម ឬសាលដីកាត្រូវចូលជាស្ថាពរ ។

កាលបើសាលក្រម ឬសាលដីកាណាមួយត្រូវបានចូលជាស្ថាពររួចហើយ គ្មានបណ្តឹងណាមួយអាចធ្វើឡើងនៅចំពោះមុខតុលាការបានឡើយ រវាងគូភាគីដដែលនោះ ប្រសិនបើបណ្តឹងនោះមានកម្មវត្ថុ និងមូលហេតុដដែល លើកលែងតែករណីបណ្តឹងសើរើ ។

## ជំពូកទី ២
## តុលាការកំពូល
### ផ្នែកទី ១
### ការចាត់តាំង

**មាត្រា ៨.-**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ។

**មាត្រា ៩.-**

តុលាការកំពូលមានសមាសភាព :

- ប្រធាន

- អនុប្រធាន
- ចៅក្រម
- នាយកក្រឡាបញ្ជី
- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅតុលាការកំពូល ។

នៅអមតុលាការកំពូល មានអង្គការអយ្យការដែលមានសមាសភាព :

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- នាយកក្រឡាបញ្ជី
- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅអង្គការអយ្យការ ។

**មាត្រា ១០.~**

តុលាការកំពូលមានសភាប្រាំ គឺ :

- សភារដ្ឋប្បវេណី
- សភាព្រហ្មទណ្ឌ
- សភារដ្ឋបាល
- សភាជម្រះក្តីពាណិជ្ជកម្ម និង
- សភាសង្គម ។

សភានីមួយៗចេញសេចក្តីសម្រេចតុលាការប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល ។

**មាត្រា ១១.~**

សភារដ្ឋប្បវេណី មានតួនាទីជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលក្រម និង សាលដីកា ឬបណ្តឹងជំទាស់ លើដីកាសម្រេចរបស់សាលាឧទ្ធរណ៍ ក្នុងរឿងក្តីរដ្ឋប្បវេណី ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

សភាព្រហ្មទណ្ឌមានតួនាទីជំនុំជម្រះលើបណ្តឹងសាទុក្ខរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

សភារដ្ឋបាលមានតួនាទីជំនុំជម្រះលើបណ្តឹងសាទុក្ខរឿងក្តីរដ្ឋបាល ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ។

សភាជម្រះក្តីពាណិជ្ជកម្ម មានតួនាទីជំនុំជម្រះលើបណ្តឹងសាទុក្ខ ក្នុងរឿងក្តីពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

សភាសង្គម មានតួនាទីជំនុំជម្រះលើបណ្តឹងសាទុក្ខ ក្នុងរឿងក្តីសង្គម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីសង្គម ។

**មាត្រា ១២.-**

សមាសភាពរបស់សភានីមួយៗ រួមមាន :

- ប្រធានសភា
- ចៅក្រម
- ក្រឡាបញ្ជី

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ។

សភានីមួយៗត្រូវមានចៅក្រមយ៉ាងតិច ៥ រូប ជាសមាជិក ដោយរួមទាំងប្រធានសភាផង ។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល ។

**មាត្រា ១៣.-**

សាលដីកាតុលាការកំពូលត្រូវចេញដោយអង្គជំនុំជម្រះនៃសភាណាមួយ ឬដោយសភាពេញអង្គ ។

**មាត្រា ១៤.-**

សមាសភាពនៃអង្គជំនុំជម្រះរបស់សភានីមួយៗត្រូវមានចៅក្រម ៥ រូប ដែលមានប្រធានមួយរូប និង ក្រឡាបញ្ជីមួយ ឬ ច្រើនរូប ។ សមាសភាពនេះ ចាំបាច់ត្រូវបំពេញដោយតំណាងអង្គការអយ្យការអមតុលាការកំពូល ចំពោះរឿងក្ដីព្រហ្មទណ្ឌ ។

ជារៀងរាល់ឆ្នាំ ប្រធានតុលាការកំពូល ត្រូវសម្រេចទុកជាមុន តាមដីកាសម្រេចនូវលំដាប់នៃការជំនួសចៅក្រម ចំពោះករណីដែលចៅក្រមនៃសភាណាមួយអវត្តមាន ឬមានធុរៈ ។

**មាត្រា ១៥.-**

សភាពេញអង្គអាចត្រូវបង្កើតឱ្យមានដំណើរការបាន កាលបើរឿងក្ដីមួយចោទឡើងនូវបញ្ហាជាគោលការណ៍ ដែលមានជាអាទិ៍ដូចជាក្នុងករណីមានដំណោះស្រាយខ្វែងគ្នារវាងចៅក្រមអង្គសេចក្ដី និងចៅក្រមអង្គសេចក្ដី ឬរវាងចៅក្រមអង្គសេចក្ដី និងតុលាការកំពូល។

នៅក្នុងរឿងព្រហ្មទណ្ឌ ការបញ្ជូនសំណុំរឿងទៅសភាពេញអង្គ ត្រូវធ្វើឡើងដាច់ខាតចំពោះបណ្ដឹងសាទុក្ខលើកទីពីរលើសាលដីកាសាលាឧទ្ធរណ៍ ដែលត្រូវបានបដិសេធ ដោយហេតុផលដដែល អនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយទៅប្រធានតុលាការកំពូល ។

សភាពេញអង្គនៃតុលាការកំពូលគឺជាអង្គជំនុំជម្រះដែលចេញសេចក្ដីសម្រេចតុលាការ។

កាលបើសភាពេញអង្គត្រូវបង្កើតឱ្យមានឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ១១ រូប ដែលបែងចែកស្មើគ្នារវាងបណ្ដាចៅក្រម នៃសភាតំណាងទាំងអស់ ។ ចៅក្រមទាំងនេះ តំណាងឱ្យសភាទាំងអស់របស់តុលាការកំពូល ។

សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

**មាត្រា ១៦.-**

សភារួមអាចត្រូវបង្កើតឱ្យមានដំណើរការបាន កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅ ក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួល ឬអាចទទួលបាននូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នា ។ សភារួមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយទៅប្រធានតុលាការកំពូល ។

សេចក្តីសម្រេចរបស់សភារួម ចំពោះការបែងចែកសមត្ថកិច្ចរវាងសភាផ្សេងៗ នៃតុលាការកំពូល និងវិវាទអំពីច្បាប់ មានអំណាចបង្ខំឱ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម ។

កាលបើសភារួមត្រូវបង្កើតឱ្យមានឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ៩ រូប ដែលបែងចែកស្មើគ្នារវាងបណ្តាចៅក្រម នៃសភាតំណាងទាំងអស់ ។ ចៅក្រមទាំងនេះតំណាងឱ្យសភាយ៉ាងតិចចំនួនពីរ នៃតុលាការកំពូល ។

សភារួមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

**មាត្រា ១៧.-**

ប្រធានតុលាការកំពូលចាត់វិធានការគ្រប់គ្រងជាចាំបាច់ សំរាប់ធានាដំណើរការប្រព្រឹត្តទៅនៃតុលាការកំពូល ។

ជារៀងរាល់ឆ្នាំ នៅក្នុងអឡុមាសទី១ នៃខែធ្នូ ប្រធានតុលាការកំពូលធ្វើដីកាសម្រេចសម្រាប់ឆ្នាំបន្ទាប់ ដើម្បី :

- បែងចែកភារកិច្ចដល់អនុប្រធានតុលាការកំពូលឱ្យទទួលបន្ទុក ធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ ។ ក្នុងករណីខ្វះអនុប្រធាន ត្រូវជ្រើសរើសចៅក្រមណាមួយអោយធ្វើជាប្រធានសភា ។
- បែងចែកភារកិច្ចដល់ចៅក្រមទៅតាមសភានីមួយៗ តាមជំនាញ ។
- បែងចែក និងផ្លាស់ប្តូរក្រឡាបញ្ជីតាមសភានីមួយៗ ។
- ចាត់តាំងចៅក្រមធ្វើជាសមាសភាពនៃអង្គជំនុំជម្រះរួមសភា ។

- ចាត់តាំងអនុប្រធានតុលាការកំពូលមួយរូបឬបើគ្មានអនុប្រធានទេ ចាត់តាំងចៅក្រមណាម្នាក់ ដើម្បីជំនួសខ្លួននៅក្នុងមុខងារដែលបានកំណត់ឱ្យ ។

ដីកាសម្រេចទាំងនេះ មិនអាចកែប្រែបានឡើយ លើកលែងតែករណីដែលចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ត្រូវឈប់ពីតំណែង ឬ ផ្លាស់ប្តូរទៅកាន់តុលាការផ្សេង ឬបន្តមានធុរៈដោយមូលហេតុឈប់សំរាករយៈពេលវែងជាដើម ។

**មាត្រា ១៨.-**

ដំណើរការនៃកិច្ចការរដ្ឋបាលរបស់តុលាការកំពូល ត្រូវធ្វើឡើងដោយកិច្ចពិភាក្សារបស់មហាសន្និបាតនៃតុលាការកំពូល ដែលពុំមែនជាអង្គជំនុំជម្រះសេចក្តី និងស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

**មាត្រា ១៩.-**

ចៅក្រមអាសនៈនៃតុលាការកំពូល ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាននេះត្រូវកំណត់ដោយ បទបញ្ជាផ្ទៃក្នុងរបស់តុលាការកំពូល ។

អគ្គលេខាធិការដ្ឋាននេះ :

- ដោះស្រាយបញ្ហាទាំងឡាយដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុង របស់ចៅក្រមអាសនៈនៃតុលាការកំពូល ។

- កំណត់ជាអាទិ៍នូវប្រតិទិននៃសវនាការ ដោយផ្អែកលើភាពចាំបាច់នៃការគ្រប់គ្រងដ៏ល្អនៃតុលាការ ។

ដំណើរការនៃអគ្គលេខាធិការដ្ឋាននេះ ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូប ដែលចាត់តាំងដោយប្រធានតុលាការកំពូល ។

បទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអសនៈនៃតុលាការកំពូល ត្រូវតាក់តែងឡើងក្រោមការដឹកនាំរបស់ប្រធានតុលាការកំពូល និងបង្ខំឱ្យចៅក្រមទាំងអស់អនុវត្ត ។

**មាត្រា ២០.-**

នៅតុលាការកំពូល មានមជ្ឈមណ្ឌលឯកសារនិងអប់រំ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានតុលាការកំពូល ។

ដំណើរការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូប ដែលត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ក្រោយពីបានពិគ្រោះយោបល់ជាមួយអគ្គព្រះរាជអាជ្ញា ។

មជ្ឈមណ្ឌលនេះ ប្រមូលផ្តុំនូវព័ត៌មានទាំងឡាយ ដែលមានសារប្រយោជន៍សំរាប់តុលាការកំពូល និងធ្វើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំរបស់តុលាការកំពូល សម្រាប់មហាសន្និបាតរបស់តុលាការនេះ ។

មជ្ឈមណ្ឌលនេះគ្រប់គ្រងកម្រងសាលកប័ត្រកណ្តាល នៃសាលដីការបស់តុលាការកំពូល និងបោះពុម្ពផ្សាយព្រឹត្តិប័ត្រសាលដីកាទាំងនេះ ។

បែបបទនៃការបោះពុម្ពផ្សាយសាលដីកា ព្រឹត្តិប័ត្រ និងភារកិច្ចរបស់មជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ។

## ផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ២១.-**

តុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើ ៖

- បណ្តឹងសាទុក្ខទាំងឡាយ ដែលសុំបដិសេធសាលក្រម ឬសាលដីការបស់តុលាការ ដោយផ្អែកលើបទប្បញ្ញត្តិស្តីពីនីតិវិធី ។

- បណ្តឹងជំទាស់ចំពោះដីកាសម្រេសរបស់សាលាឧទ្ធរណ៍ ក្នុងរឿងរដ្ឋប្បវេណី ។

- បណ្តឹងសើរើចំពោះសាលក្រម ឬសាលដីកាស្ថាពរ លើកលែងតែមានបទបញ្ញាត្តិផ្សេងចែងផ្ទុយពីនេះ ។

- ភាពមិនច្បាស់លាស់នៃដែនសមត្ថកិច្ចរបស់តុលាការថ្នាក់ក្រោមក្នុងរឿងរដ្ឋប្បវេណី ដោយអនុលោមតាមនីតិវិធីរដ្ឋប្បវេណី និងបញ្ហាផ្សេងទៀតដែលច្បាប់បានកំណត់ ។

តុលាការកំពូលអាចមានអំណាចពិសេស ដែលកំណត់ដោយច្បាប់ផ្សេងទៀត ។

តុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើអង្គច្បាប់ ពុំមានសមត្ថកិច្ចជមនុំជម្រះលើអង្គហេតុឡើយ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ។

## ផ្នែកទី ៣
## អង្គការអយ្យការ

### មាត្រា ២២.-

មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។ តំណាងអយ្យការត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្ដីព្រហ្មទណ្ឌ ។

ក្រៅពីរឿងក្ដីព្រហ្មទណ្ឌ កាលបើផលប្រយោជន៍សាធារណៈត្រូវចោទជាបញ្ហានេះ តំណាងអយ្យការអាចផ្ដល់យោបល់នៅក្នុងសវនាការ ប្រសិនបើខ្លួនយល់ថាចាំបាច់ ឬតាមការស្នើសុំរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមាន ។

### មាត្រា ២៣.-

មុខងាររបស់អង្គការអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ទៅឱ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តន៍មុខងារនេះក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញា ។

### មាត្រា ២៤.-

អគ្គព្រះរាជអាជ្ញា មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាបែងចែកអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលនៅក្នុងក្រុមការងារផ្សេងៗ នៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។

សេចក្ដីសនិដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញា ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញានៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញា មិនយល់ព្រមលើ

សេចក្តីសន្និដ្ឋាននោះទេ ហើយម្ចាស់នៃសេចក្តីសន្និដ្ឋាននោះនៅតែមានះ អគ្គព្រះរាជអាជ្ញា អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តង ឱ្យធ្វើជាតំណាងអង្គការអយ្យការនៅក្នុងសវនាការព្រហ្មទណ្ឌ ។

ប៉ុន្តែនៅក្នុងពេលសវនាការព្រហ្មទណ្ឌ ចៅក្រមអយ្យាការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនឃើញថាស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន លើការបកស្រាយ និងការអនុវត្តច្បាប់ ។

**មាត្រា ២៥.-**

អង្គការអយ្យការមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ដែលត្រូវទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់អង្គការអយ្យការ ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អង្គការអយ្យការ ។

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយចៅក្រមអយ្យការមួយរូប ដែលចាត់តាំងដោយអគ្គព្រះរាជអាជ្ញា ។

បទបញ្ជាផ្ទៃក្នុងរបស់អង្គការអយ្យការ ត្រូវតាក់តែងឡើងក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងត្រូវបង្ខំឱ្យចៅក្រមអយ្យការទាំងអស់គោរពតាម ។

## ផ្នែកទី ៤
## សភារដ្ឋបាល

**មាត្រា ២៦.-**

សភារដ្ឋបាលនៃតុលាការកំពូល មានសមាសភាពជាចៅក្រម និងទីប្រឹក្សារដ្ឋបាល ។

ទីប្រឹក្សារដ្ឋបាលមានចំនួនយ៉ាងតិច ៥ រូប ដែលត្រូវជ្រើសតាំងឡើងដោយអនុលោមតាមច្បាប់នេះ ។

**មាត្រា ២៧.-**

ទីប្រឹក្សារដ្ឋបាលត្រូវជ្រើសរើសនៅក្នុងចំណោមសមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

សមាជិកទាំងនេះ ត្រូវមានសញ្ញាប័ត្រឧត្តមសិក្សាខាងវិស័យច្បាប់ វិស័យរដ្ឋបាល ឬសញ្ញាប័ត្រដែលមានតំលៃសមមូលផ្សេងទៀត និងត្រូវមានបទពិសោធន៍ការងារយ៉ាងតិចប្រាំឆ្នាំនៅក្នុងក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ២៨.-**

ទីប្រឹក្សារដ្ឋបាល ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាននៃក្រុមប្រឹក្សាអ្នកច្បាប់ ។

មុនចូលកាន់មុខតំណែង ទីប្រឹក្សារដ្ឋបាលត្រូវស្បថនៅសាលាឧទ្ធរណ៍ ។

ទីប្រឹក្សារដ្ឋបាល ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភារដ្ឋបាលនៃតុលាការកំពូលឡើយ ។ ទីប្រឹក្សារដ្ឋបាល ត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅតុលាការកំពូល តាមការអញ្ជើញរបស់ប្រធានសភារដ្ឋបាល ។

**មាត្រា ២៩.-**

នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាទីប្រឹក្សារដ្ឋបាល នៅក្នុងសភារដ្ឋបាលនៃតុលាការកំពូល សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៅតែស្ថិតនៅក្រោមលក្ខន្តិកៈនៃមុខងារសាធារណៈ ។

នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាទីប្រឹក្សារដ្ឋបាល នៅក្នុងសភារដ្ឋបាល នៃតុលាការកំពូល សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ពុំតាំងខ្លួនជាតំណាងរបស់ក្រុមប្រឹក្សាអ្នកច្បាប់ និងពុំស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ស្ថាប័ននេះឡើយ ។

**មាត្រា ៣០.-**

សាលដីការបស់សភារដ្ឋបាល ត្រូវសម្រេចដោយចៅក្រមប្រាំរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សារដ្ឋបាលចំនួនពីររូប ។

ទីប្រឹក្សារដ្ឋបាលចូលរួមនៅក្នុងសវនាការ និងអាចចោទសួរចំពោះភាគី ឬសាក្សីតាមរយៈប្រធានសវនាការ ប៉ុន្តែពុំមានសិទ្ធិចូលរួមពិភាក្សាសម្រេចសេចក្តីឡើយ ។

# ជំពូកទី ៣

# សាលាឧទ្ធរណ៍

## ផ្នែកទី ១

## ការចាត់តាំង

**មាត្រា ៣១.-**

សមាសភាពសាលាឧទ្ធរណ៍រួមមាន :

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- នាយកក្រឡាបញ្ជី
- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបំរើការនៅសាលាឧទ្ធរណ៍ ។

នៅអមសាលាឧទ្ធរណ៍ មានអង្គការអយ្យការ ដែលមានសមាសភាព:

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- នាយកក្រឡាបញ្ជី
- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅអង្គការអយ្យការ ។

**មាត្រា ៣២.-**

សាលាឧទ្ធរណ៍មានសភា ៦ គឺ:

- សភារដ្ឋប្បវេណី
- សភាព្រហ្មទណ្ឌ

- សភាស៊ើបសួរ
- សភារដ្ឋបាល
- សភាជម្រះក្តីពាណិជ្ជកម្ម និង
- សភាសង្គម ។

សភានីមួយៗចេញសេចក្តីសម្រេចតុលាការប្រកបដោយស្វ័យភាព ក្នុងនាមសាលាឧទ្ធរណ៍ ។

**មាត្រា ៣៣.-**

សភារដ្ឋប្បវេណីមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង ក្នុងរឿងក្តីរដ្ឋប្បវេណី ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

សភាព្រហ្មទណ្ឌមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

សភាស៊ើបសួរមានតួនាទីជំនុំជម្រះតែលើរឿងទាំងឡាយណាដែលបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌប្រគល់ឱ្យ ។

សភារដ្ឋបាលមានតួនាទីជុំនំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងក្តីរដ្ឋបាល ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ។

សភាជម្រះក្តីពាណិជ្ជកម្មមានតួនាទីជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍រឿងក្តីពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

សភាសង្គម មានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងក្តីសង្គម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីសង្គម ។

**មាត្រា ៣៤.-**

សភាស៊ើបសួរសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីដីការបស់ចៅក្រមស៊ើបសួរ ។ ក្នុងករណីនេះ សភាស៊ើបសួរមានសមត្ថកិច្ចយ៉ាងពេញលេញ ដើម្បីធ្វើការស៊ើបសួរ ដោយអនុលោមតាមវិធានកំណត់ដោយបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

វិធានស្តីពីសមត្ថកិច្ច ការរៀបចំ និងដំណើរការរបស់សភាស៊ើបសួរ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៣៥.-**

សមាសភាពរបស់សភានីមួយៗ រួមមាន :

-ប្រធានសភា

-ចៅក្រម

-ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ។

សភានីមួយៗត្រូវមានចៅក្រមយ៉ាងតិច ៥ រូបជាសមាជិក ដោយរួមទាំងប្រធានសភាផង ។

ចំនួនចៅក្រម ក្រឡាបញ្ជី និង ដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ៣៦.-**

សាលដីកាសាលាឧទ្ធរណ៍ ត្រូវចេញដោយអង្គជំនុំជម្រះនៃសភាណាមួយនៃសាលាឧទ្ធរណ៍ ។

**មាត្រា ៣៧.-**

សមាសភាពនៃអង្គជំនុំជម្រះរបស់សភានីមួយៗត្រូវមានចៅក្រម ០៣ រូប ដែលមានប្រធានមួយរូប និងក្រឡាបញ្ជីមួយ ឬច្រើនរូប ។

ប៉ុន្តែ កាលបើសភាព្រហ្មទណ្ឌសម្រេច អំពីរឿងឧក្រិដ្ឋនោះ សាលដីកាត្រូវសម្រេចដោយចៅក្រម ០៥ រូប រាប់ទាំងប្រធានសភាផង ។

រឿងក្តីណាដែលតុលាការកំពូលបានបង្វិលមកវិញនោះ សាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម ០៣រូប ឬប្រសិនបើជារឿងឧក្រិដ្ឋវិញ នោះត្រូវ

ជំនុំជម្រះដោយចៅក្រម ០៥រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន ។

សមាសភាពនេះ ចាំបាច់ត្រូវបំពេញដោយតំណាងអង្គការអយ្យការអមសាលាឧទ្ធរណ៍ ចំពោះគ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់ ។

ជារៀងរាល់ឆ្នាំ ប្រធានសាលាឧទ្ធរណ៍ ត្រូវសម្រេចទុកជាមុន តាមដីកាសម្រេចនូវលំដាប់នៃការជំនួសចៅក្រម ចំពោះករណីដែលចៅក្រមនៃសភាណាមួយអវត្តមាន ឬមានធុរៈ ។

**មាត្រា ៣៨.-**

សភារួមអាចត្រូវបង្កើតឱ្យមានដំណើរការបាន កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួល ឬអាចទទួលបាននូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នា ។ សភារួមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍ ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយទៅប្រធានសាលាឧទ្ធរណ៍ ។

សេចក្តីសម្រេចរបស់សភារួម ចំពោះការបែងចែកសមត្ថកិច្ចរវាងសភាផ្សេងៗនៃ សាលាឧទ្ធរណ៍ និងវិវាទច្បាប់ មានអំណាចបង្ខំឱ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម ។

កាលបើសភារួមត្រូវបង្កើតឱ្យមានឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ៧រូប ដែលបែងចែកស្មើគ្នារវាងបណ្តាចៅក្រមនៃសភាតំណាងទាំងអស់ ។ ចៅក្រមទាំងនេះតំណាងឱ្យសភាយ៉ាងតិចចំនួនពីរនៃសាលាឧទ្ធរណ៍ ។ សភាស៊ើបសួរពុំអាចចូលរួមបង្កើតសភារួមបានឡើយ ។

សភារួមស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

**មាត្រា ៣៩.-**

ដំណើរការនៃកិច្ចការរដ្ឋបាលរបស់សាលាឧទ្ធរណ៍ ត្រូវធ្វើឡើងដោយកិច្ចពិភាក្សារបស់មហាសន្និបាតនៃ សាលាឧទ្ធរណ៍ដែលពុំមែនជាអង្គជំនុំជម្រះសេចក្តី និងស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ៤០.-**

ប្រធានសាលាឧទ្ធរណ៍ចាត់វិធានការគ្រប់គ្រងជាចាំបាច់ ក្នុងការប្រព្រឹត្តិទៅនៃសាលាឧទ្ធរណ៍ ជាពិសេស ជារៀងរាល់ឆ្នាំ នៅក្នុងអឌ្ឍមាសទីមួយនៃខែធ្នូ ប្រធានសាលាឧទ្ធរណ៍ត្រូវចេញដីកាសម្រេច សម្រាប់ឆ្នាំបន្ទាប់ខាងមុខ :

-ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ម្នាក់ ឬបើគ្មានអនុប្រធាននេះទេ ចាត់តាំងចៅក្រមម្នាក់ដើម្បីជំនួស ខ្លួននៅក្នុងមុខងារដែលខ្លួនប្រគល់ឱ្យជាពិសេសនោះ ប្រសិនបើជាការគួរ ។

- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ឱ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗតាមជំនាញឯកទេស ។ ក្នុងករណីខ្វះ ឬពុំមានអនុប្រធានសាលាឧទ្ធរណ៍ ចៅក្រមអាចត្រូវបានចាត់តាំងប្រធានសភាបាន ។

-បែងចែកអនុប្រធានសាលាឧទ្ធរណ៍ និងចៅក្រម និងផ្លាស់ប្តូរក្រឡាបញ្ជីទៅតាមសភានីមួយៗ ។

-កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងសភា និងក្នុងអង្គជំនុំជម្រះ ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ។

-ចាត់តាំងចៅក្រមដែលត្រូវចូលរួមជាសមាសភាពនៅក្នុងពេលសវនាការជំនុំជម្រះរឿងដែលតុលាការកំពូលបានបង្វិលមកវិញ ។

-កំណត់ចំនួនថ្ងៃ និង ប្រភេទនៃសវនាការ ។

**មាត្រា ៤១.-**

ចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ដែលទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអសនៈនៃសាលាឧទ្ធរណ៍ ។

អគ្គលេខាធិការរដ្ឋបាលរបស់ចៅក្រមអសនៈនៃសាលាឧទ្ធរណ៍ ដោះស្រាយបញ្ហាដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអសនៈនៃសាលាឧទ្ធរណ៍ ។

អគ្គលេខាធិការដ្ឋាននៃចៅក្រមអសនៈកំណត់ជាអាទិ៍នូវប្រតិទិននៃសវនាការ ដោយផ្អែកលើភាពចាំបាច់នៃការគ្រប់គ្រងដ៏ល្អផ្នែកតុលាការ ។

ដំណើរការរបស់អគ្គលេខាធិការដ្ឋាននៃចៅក្រមអសនៈស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូបដែលត្រូវបានចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ។

បទបញ្ជាផ្ទៃក្នុងចៅក្រមអសនៈនៃសាលាឧទ្ធរណ៍ ត្រូវតាក់តែងឡើងក្រោមការដឹកនាំរបស់ប្រធានសាលាឧទ្ធរណ៍ និងបង្ខំឱ្យចៅក្រមទាំងអស់អនុវត្តតាម ។

## ផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ៤២.‑**

សាលាឧទ្ធរណ៍មានទីតាំងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលមានច្បាប់បង្កើតសាលាឧទ្ធរណ៍តាមតំបន់ទៀតនោះ សាលាឧទ្ធរណ៍ចាស់ដែលបានទទួលបណ្ដឹងរួចមកហើយ ហើយកំពុងចាត់ការ នៅតែមានសមត្ថកិច្ចដដែលដើម្បីសម្រេចសេចក្ដី ។ ប៉ុន្តែ សំណុំរឿងទាំងឡាយណាដែលសាលាឧទ្ធរណ៍ចាស់បានទទួលហើយពុំទាន់បានចាត់ការ ត្រូវផ្ទេរជាស្វ័យប្រវត្តិជូនសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច ។

**មាត្រា ៤៣.‑**

សាលាឧទ្ធរណ៍សម្រេចដោយឯករាជ្យ អំពីអង្គសេចក្ដីនៃរឿង ។

សាលាឧទ្ធរណ៍មានសមត្ថកិច្ច សម្រេចលើករណីដូចតទៅ :

-រឿងក្ដីណាដែលតុលាការកំពូលបានបង្វិលមកវិញ ។

- សាលក្រមជំនុំជម្រះលើកទីមួយ ដោយសាលាដំបូង នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។

- ការប្រកែកតវ៉ាពីសមត្ថកិច្ចរបស់តុលាការជាន់ទី ១ និងអំពីវិវាទសមត្ថកិច្ចរវាងតុលាការជាន់ទី ១ ទាំងឡាយ លើកលែងតែក្នុងករណីមានច្បាប់ផ្សេងពីនេះ។

- បណ្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់តុលាការយោធា ។

-បណ្តឹងតវ៉ាអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នៅក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈមេធាវី ។

- បណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង អំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តនូវសេចក្តីសម្រេចរបស់មជ្ឈត្តករ ។

-ពាក្យសុំឱ្យចេញឱកាសទានអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

-អំពីបញ្ហាផ្សេងទៀត ដែលច្បាប់បានកំណត់ ។

## ផ្នែកទី ៣
## អង្គការអយ្យការ

**មាត្រា ៤៤.-**

មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ តំណាងអយ្យការត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ។

ក្រៅពីរឿងក្តីព្រហ្មទណ្ឌ កាលបើផលប្រយោជន៍សាធារណៈត្រូវចោទជាបញ្ហានោះ តំណាងអយ្យការអាចផ្តល់យោបល់ក្នុងសវនាការ ប្រសិនបើខ្លួនយល់ថាចាំបាច់ ឬតាមការស្នើសុំរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

**មាត្រា ៤៥.-**

មុខងាររបស់អង្គការអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចូលរួមអនុវត្តន៍មុខងារនេះក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញា ។

**មាត្រា ៤៦.-**

អគ្គព្រះរាជអាជ្ញា មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា បែងចែកអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅក្នុងក្រុមការងារផ្សេងៗ នៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ច នៃដែនដីរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាអោយចោទប្រកាន់ ឬក៏ចាត់អោយចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ ។

ប៉ុន្តែ នៅក្នុងពេលសវនាការព្រហ្មទណ្ឌ អគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាមួយរូបធ្វើសេចក្ដីសន្និដ្ឋាននៅគ្រប់រឿងទាំងអស់ ដោយផ្ដល់យោបល់របស់ខ្លួន ស្ដីអំពីការបកស្រាយ និងការអនុវត្តច្បាប់ ។

**មាត្រា ៤៧.-**

អង្គការអយ្យការមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ដែលត្រូវទទួលបន្ទុកកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុរបស់អង្គការអយ្យការ ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយបទបញ្ញាផ្ទៃក្នុងរបស់អង្គការអយ្យការ ។

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយចៅក្រមអយ្យការមួយរូប ដែលចាត់តាំងដោយអគ្គព្រះរាជអាជ្ញា ។

បទបញ្ញាផ្ទៃក្នុងរបស់អង្គការអយ្យការ ត្រូវតាក់តែងឡើងក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងត្រូវបង្ហំឱ្យចៅក្រមអយ្យការទាំងអស់គោរពតាម ។

## ផ្នែកទី ៤ សភារដ្ឋបាល

**មាត្រា ៤៨.-**

សភារដ្ឋបាលនៃសាលាឧទ្ធរណ៍ មានសមាសភាពជាចៅក្រម និងទីប្រឹក្សារដ្ឋបាល ។

ទីប្រឹក្សារដ្ឋបាលមានចំនួនយ៉ាងតិច ៥ រូប ដែលត្រូវជ្រើសតាំងឡើងដោយអនុលោមតាមច្បាប់នេះ ។

**មាត្រា ៤៩.-**

ទីប្រឹក្សារដ្ឋបាលត្រូវជ្រើសរើសនៅក្នុងចំណោមសមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

សមាជិកទាំងនេះ ត្រូវមានសញ្ញាប័ត្រឧត្តមសិក្សាខាងវិស័យច្បាប់ រដ្ឋបាល ឬសញ្ញាប័ត្រ ដែលមានតំលៃសមមូលផ្សេងទៀត និងត្រូវមានបទពិសោធន៍ការងារយ៉ាងតិចប្រាំឆ្នាំនៅក្នុងក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ៥០.-**

ទីប្រឹក្សារដ្ឋបាលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាននៃក្រុមប្រឹក្សាអ្នកច្បាប់ ។

មុនចូលកាន់មុខតំណែង ទីប្រឹក្សារដ្ឋបាលត្រូវស្បថនៅសាលាឧទ្ធរណ៍ ។

ទីប្រឹក្សារដ្ឋបាល ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភារដ្ឋបាលនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សារដ្ឋបាល ត្រូវចូលមកបំពេញមុខងាររបស់ខ្លួន នៅសាលាឧទ្ធរណ៍ តាមការអញ្ជើញរបស់ប្រធានសភារដ្ឋបាល ។

**មាត្រា ៥១.-**

នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាទីប្រឹក្សារដ្ឋបាល នៅសភារដ្ឋបាលនៃសាលាឧទ្ធរណ៍ សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៅតែស្ថិតនៅក្រោមលក្ខន្តិកៈនៃមុខងារសាធារណៈ ។

នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាទីប្រឹក្សារដ្ឋបាលនៅ សភារដ្ឋបាលនៃសាលាឧទ្ធរណ៍ សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ពុំតាំងខ្លួនជាតំណាងរបស់ក្រុមប្រឹក្សាអ្នកច្បាប់ និងពុំស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ស្ថាប័ននេះឡើយ ។

**មាត្រា ៥២.-**

សាលក្រមរបស់សភារដ្ឋបាល ត្រូវសម្រេចដោយចៅក្រមបីរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សារដ្ឋបាលចំនួនពីររូប ។

ទីប្រឹក្សារដ្ឋបាលចូលរួមនៅក្នុងសវនាការ និងអាចចោទសួរចំពោះភាគីឬសាក្សី តាមរយៈប្រធានសវនាការ ប៉ុន្តែពុំមានសិទ្ធិចូលរួមពិភាក្សាសម្រេចសេចក្តីឡើយ ។

## ជំពូកទី ៤

## សាលាដំបូង

### ផ្នែកទី ១ : បទប្បញ្ញត្តិទូទៅ

### អនុផ្នែកទី ១ : ការចាត់តាំង

**មាត្រា ៥៣.-**

សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ដំបូងដែលមានទីតាំងនៅតាមខេត្ត និងក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៤.-**

សមាសភាពសាលាដំបូងរួមមាន :

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- នាយកក្រឡាបញ្ជី
- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបំពីការនៅសាលាដំបូង ។

នៅអមសាលាដំបូង មានអង្គការអយ្យការដែលមានសមាសភាព :

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- នាយកក្រឡាបញ្ជី

- នាយករងក្រឡាបញ្ជី
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាលផ្សេងទៀតដែលបម្រើការនៅអង្គការអយ្យការ ។

**មាត្រា ៥៥.-**

សាលាដំបូងមានសភា ៥ គឺ :

- សភារដ្ឋប្បវេណី
- សភាព្រហ្មទណ្ឌ
- សភារដ្ឋបាល
- សភាជម្រះក្តីពាណិជ្ជកម្ម និង
- សភាសង្គម ។

សភានីមួយៗចេញសេចក្តីសម្រេចតុលាការប្រកបដោយស្វ័យភាព ក្នុងនាមសាលាដំបូងដែលសភានោះស្ថិតនៅ ។

**មាត្រា ៥៦.-**

សភារដ្ឋប្បវេណីមានតួនាទីជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំងឡាយណាដែលពុំមានបទប្បញ្ញត្តិ ណាមួយប្រគល់សមត្ថកិច្ចទៅឱ្យសភាផ្សេងទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

សភាព្រហ្មទណ្ឌមានតួនាទីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

សភារដ្ឋបាលមានតួនាទីជុំនំជម្រះរឿងក្តីរដ្ឋបាល ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ។

សភាជម្រះក្តីពាណិជ្ជកម្មមានតួនាទីជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

សភាសង្គម មានតួនាទីជំនុំជម្រះរឿងក្តីសង្គម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីសង្គម ។

**មាត្រា ៥៧.-**

សមាសភាពរបស់សភានីមួយៗ រួមមាន :

- ប្រធានសភា
- ចៅក្រម
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង ។

សភានីមួយៗត្រូវមានចៅក្រមយ៉ាងតិច ៥ រូប ជាសមាជិក ដោយរួមទាំងប្រធានសភាផង ។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាដំបូង ។

**មាត្រា ៥៨.-**

សាលាដំបូងសម្រេចសេចក្តីដោយមានចៅក្រមមួយ (០១)រូប ទៅបី (០៣) រូប អនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិស្តីពីនីតិវិធីផ្សេងទៀត ។

ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ លំដាប់នៃការផ្លាស់ប្តូរ ត្រូវធ្វើតាមដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានតុលាការ ។ ក្នុងករណីដែលសភាណាមួយមិនអាចបើកសវនាការបាន ដោយមានមូលហេតុមកពីខ្វះចៅក្រម ប្រធានសាលាដំបូង ត្រូវស្នើសុំទៅប្រធានតុលាការកំពូល ដើម្បីចាត់ចៅក្រមម្នាក់ ឬ ច្រើននាក់នៃសាលាដំបូងដែលនៅជិតជាងគេ សំរាប់បំពេញសមាសភាពនៃសភានេះ ។

**មាត្រា ៥៩.-**

ប្រធានសាលាដំបូងចាត់វិធានការគ្រប់គ្រងជាចាំបាច់សំរាប់ដំណើរការនៃសាលាដំបូង។ ជារៀងរាល់ឆ្នាំនៅក្នុងអឌ្ឍមាសទី ១ នៃខែធ្នូ ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចសម្រាប់ឆ្នាំបន្ទាប់ខាងមុខ ដើម្បី :

-បែងចែកអនុប្រធាននៃសាលាដំបូង ឱ្យធ្វើជាប្រធានសភា ទៅតាមឯកទេសរបស់ខ្លួន និងបែងចែកចៅក្រមសំរាប់ធ្វើជាសមាជិកនៅក្នុងសភាទាំងនោះ ។

- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងសភានីមួយៗ និងនៅក្នុងអង្គជំនុំជម្រះនៃសភាទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ។

-ផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុង សភានីមួយៗ ។

-កំណត់អំពីថ្ងៃ និងប្រភេទនៃសវនាការ ។

ដីកាទាំងនេះមិនអាចកែប្រែបានឡើយនៅក្នុងពេលកំពុងប្រតិបត្តិ លើកលែងតែករណីចាំបាច់ ។ ការកែប្រែនេះ ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានតុលាការ ។

**មាត្រា ៦០.-**

ជារៀងរាល់ឆ្នាំ ប្រធានសាលាដំបូងចាត់តាំងចៅក្រមស៊ើបសួរម្នាក់ ឬច្រើននាក់ដែលមានសមត្ថកិច្ច ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចទទួលបំពេញមុខការផ្សេងៗទៀតតាមការចាត់ តាមរបស់ប្រធានតុលាការ ។

នៅក្នុងករណីណាក៏ដោយ ចៅក្រមស៊ើបសួរមិនអាចជំនុំជម្រះរឿង ដែលទាក់ទងនឹងរឿងដែលខ្លួនបានស៊ើបសួរបានឡើយ ។

**មាត្រា ៦១.-**

ដំណើរការនៃកិច្ចការរដ្ឋបាលរបស់សាលាដំបូង ត្រូវប្រព្រឹត្តទៅដោយការពិភាក្សារបស់មហាសន្និបាតរបស់សាលាដំបូង ក្រោមអធិបតីភាពរបស់ប្រធានសាលាដំបូង ។

**មាត្រា ៦២.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចតាមប្រកាសអនុញ្ញាតឱ្យសាលាដំបូងបើកសវនាការចល័តនៅក្នុងឃុំណាមួយ ឬច្រើន ក្រៅពីឃុំដែលសាលាដំបូងនោះមានទីស្នាក់ការតាំងនៅតាមការស្នើរសុំពីប្រធានសាលាដំបូង ។

## អនុផ្នែកទី ២

## សមត្ថកិច្ច

**មាត្រា ៦៣.-**

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត ។

សាលាដំបូងមានសមត្ថកិច្ចសម្រេចផ្តល់ឱកាសទាន ឱ្យអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករជាតិ ឬសេចក្តីសម្រេចតុលាការបរទេស ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

ក្នុងករណីមានបញ្ហាបែងចែកសមត្ថកិច្ចរវាងសភាផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូង ចេញដីកាសម្រេច ដើម្បីប្រគល់រឿងក្តីនោះទៅសភាដែលប្រធានសាលាដំបូងយល់ថាមានសមត្ថកិច្ច ។

## អនុផ្នែកទី ៣
## អង្គការអយ្យការ

**មាត្រា ៦៤.-**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ តំណាងអយ្យការត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ។

ក្រៅពីរឿងក្តីព្រហ្មទណ្ឌ កាលបើផលប្រយោជន៍សាធារណៈត្រូវចោទជាបញ្ហានោះ តំណាងអយ្យការអាចផ្តល់យោបល់នៅក្នុងសវនាការ ប្រសិនបើខ្លួនយល់ថាចាំបាច់ ឬតាមការស្នើសុំរបស់តុលាការដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

**មាត្រា ៦៥.-**

មុខងាររបស់អង្គការអយ្យការសាលាដំបូង ត្រូវបានប្រគល់អោយព្រះរាជអាជ្ញាអមសាលាដំបូង ។

ព្រះរាជអាជ្ញារងអមសាលាដំបូង ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ។

**មាត្រា ៦៦.-**

ព្រះរាជអាជ្ញាមានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលមានក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ព្រះរាជអាជ្ញាបែងចែកព្រះរាជអាជ្ញារងអមសាលាដំបូង នៅក្នុងក្រុមការងារផ្សេងៗនៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។ ព្រះរាជាអជ្ញាអាចធ្វើអធិបញ្ញាអោយចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់អោយធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្តីសន្និដ្ឋាន យ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ ។

## ផ្នែកទី ២ : បទប្បញ្ញត្តិសម្រាប់អនុវត្តចំពោះ សភារដ្ឋបាល សភាជម្រះក្តីពាណិជ្ជកម្ម និងសភាសង្គម នៃសាលាដំបូង

## អនុផ្នែកទី ១

## សភារដ្ឋបាល

## កថាភាគទី ១

## ការចាត់តាំង

**មាត្រា ៦៧.-**

សភារដ្ឋបាលមានសមាសភាពជាចៅក្រម ដែលត្រូវស្ថិតនៅក្រោមលក្ខន្តិកៈ នៃអង្គចៅក្រម ។

ប្រធានសភារដ្ឋបាលគឺជាចៅក្រមដែលត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង ។

**មាត្រា ៦៨.-**

សាលក្រមរបស់សភារដ្ឋបាលត្រូវសម្រេចដោយអង្គជំនុំជម្រះ ដែលមានសមាសភាពជាចៅក្រមបីរូប លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ ។

## កថាភាគទី ២

## សមត្ថកិច្ច

**មាត្រា ៦៩.-**

សភារដ្ឋបាលនៃសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះវិវាទរដ្ឋបាល ។

ដោយអនុលោមតាមមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា វិវាទរដ្ឋបាល គឺជាទំនាស់រវាងរូបវន្តបុគ្គល ឬនីតិបុគ្គល ជាមួយសស្ថាប័នរដ្ឋបាល ។

**មាត្រា ៧០.-**

សភារដ្ឋបាលនៃសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលកើតចេញ ពីសេចក្តីសម្រេចរបស់អាជ្ញាធររដ្ឋបាលដែលតាំងនៅក្នុងដែនដីនៃសាលាដំបូងនោះ ។

ចំពោះអចលនវត្ថុ ដើមបណ្តឹងអាចប្តឹងតុលាការនៃទីកន្លែងរបស់អចលនវត្ថុ ឬតុលាការនៃទីកន្លែង ដែលអាជ្ញាធររដ្ឋបាលពាក់ព័ន្ធតាំងនៅ ។

**មាត្រា ៧១.-**

សេចក្តីសម្រេចរបស់សភារដ្ឋបាលនៃសាលាដំបូង បើកផ្លូវប្តឹងឧទ្ធរណ៍ ។

បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជម្រះដោយសភារដ្ឋបាលនៃសាលាឧទ្ធរណ៍ ។

បណ្តឹងសាទុក្ខ ត្រូវជំនុំជម្រះដោយសភារដ្ឋបាលនៃតុលាការកំពូល ។

**មាត្រា ៧២.-**

អាជ្ញាធររដ្ឋបាលទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន និងសេចក្តីសម្រេចដែលខ្លួនបានចេញ ។

**មាត្រា ៧៣.-**

ដោយអនុលោមតាមគោលការណ៍នីត្យានុកូលភាព សភារដ្ឋបាលអាចចេញសាលក្រមសម្រេចទុកជាមោឃៈចំពោះសេចក្តីសម្រេចដែលចេញដោយអាជ្ញាធររដ្ឋបាល ។ ករណីដែលនាំឱ្យប្រកាសមោឃកម្ម គឺអសមត្ថកិច្ច វិការៈផ្នែកទម្រង់ ការរំលោភអំណាច និងការបំពានច្បាប់ ។

## អនុជំពូកទី ២
## សភាជម្រះក្តីពាណិជ្ជកម្ម
## កថាភាគទី ១
## ការចាត់តាំង

**មាត្រា ៧៤.-**

សភាជម្រះក្តីពាណិជ្ជកម្ម មានសមាសភាពជាចៅក្រម និងទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវបោះឆ្នោតជ្រើសតាំងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៧៥.-**

សាលក្រមរបស់សភាជម្រះក្តីពាណិជ្ជកម្ម ត្រូវសម្រេចដោយចៅក្រមមួយរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្មពីររូប ។

**មាត្រា ៧៦.-**

ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិពីរឆ្នាំ តាមល័ក្ខខ័ណ្ឌដែលមានកំណត់ខាងក្រោមនេះ ។

ទីប្រឹក្សាពាណិជ្ជកម្មទាំងនេះ អាចត្រូវបោះឆ្នោតជ្រើសតាំងឡើងសាជាថ្មីបានតែបីអាណត្តិប៉ុណ្ណោះ ។

កាលបើអាណត្តិរបស់ទីប្រឹក្សាពាណិជ្ជកម្មខាងលើនេះ ត្រូវបានផុតនៅមុនពេលកំណត់សំរាប់ជ្រើសតាំងអ្នកបន្តវេន ទីប្រឹក្សាពាណិជ្ជកម្មនេះត្រូវនៅបំពេញមុខងារដដែល រហូតពេលណាដែលមានការជ្រើសតាំងអ្នកបន្តវេន ។ ការបន្តអាណត្តិនេះមិនត្រូវអូសបន្លាយឱ្យលើសពី ០៣ ខែ ឡើយ ។

**មាត្រា ៧៧.-**

មុនចូលកាន់មុខតំណែង ទីប្រឹក្សាពាណិជ្ជកម្មត្រូវស្បថនៅសាលាឧទ្ធរណ៍ ។

ទីប្រឹក្សាពាណិជ្ជកម្ម ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាជម្រះក្តីពាណិជ្ជកម្ម នៃសាលាដំបូងឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានសភាជម្រះក្តីពាណិជ្ជកម្ម ។

**មាត្រា ៧៨.-**

មុខងាររបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវបញ្ចប់នៅពេល :

- ផុតអាណត្តិ លើកលែងតែមានការពន្យារដូចមានចែងនៅក្នុងមាត្រា ៧៦ នៃច្បាប់នេះ ។
- លាលែង ឬធ្លាក់ពីមុខងារ ។

**មាត្រា ៧៩.-**

កាលបើនីតិវិធីជម្រះបញ្ជីតាមផ្លូវតុលាការ ឬនីតិវិធីស្តារ ត្រូវបានផ្តើមអនុវត្តទៅលើទីប្រឹក្សាពាណិជ្ជកម្មណាម្នាក់ ទីប្រឹក្សាពាណិជ្ជកម្មរូបនេះ ត្រូវឈប់ពីមុខងារ របស់ខ្លួនគិតពីថ្ងៃចេញសាលក្រមផ្តើមនីតិវិធីនោះ ។ ទីប្រឹក្សាពាណិជ្ជកម្មរូបនេះ ត្រូវចាត់ទុកថាបានលាលែងពីមុខតំណែង ។

បទប្បញ្ញត្តិដដែលនេះ ត្រូវអនុវត្តទៅលើទីប្រឹក្សាពាណិជ្ជកម្ម ដែលជាសមាជិកនៃក្រុមហ៊ុនដែលជាកម្មវត្ថុនៃនីតិវិធីធ្វើការជម្រះបញ្ជី ឬធ្វើការស្តារផងដែរ ។

**មាត្រា ៨០.-**

ទីប្រឹក្សាពាណិជ្ជកម្ម បំពេញមុខងាររបស់ខ្លួនដោយទទួលកំរៃទៅតាមថ្ងៃដែលខ្លួនបានបំពេញមុខងារជាទីប្រឹក្សាពាណិជ្ជកម្ម នៅក្នុងសភាជម្រះក្តីពាណិជ្ជកម្មនៃសាលាដំបូង ។ ប្រាក់កំរៃនេះត្រូវគណនាទៅតាមសមាមាត្រនៃបៀវត្ស និងប្រាក់បំណាច់ទាំងអស់របស់ចៅក្រមដែលមានឋានន្តរស័ក្តិទាបជាងគេ នៃសភាជម្រះក្តីពាណិជ្ជកម្ម ។

## កថាភាគទី ២
## ការជ្រើសតាំងទីប្រឹក្សាពាណិជ្ជកម្ម

**មាត្រា ៨១.-**

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវរៀបចំដោយគណៈកម្មការរៀបចំការបោះឆ្នោត ដែលមានសមាសភាព :

- តំណាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ០១ ជាប្រធាន
- តំណាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ០១ រូប ជាសមាជិក
- តំណាងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ០១ រូប ជាសមាជិក
- តំណាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប ជាសមាជិក ។

**មាត្រា ៨២.-**

គណៈកម្មការរៀបចំការបោះឆ្នោតដែលមានចែងនៅក្នុងមាត្រា ៨១ ខាងលើនេះ មានភារកិច្ចធានាឱ្យការបោះឆ្នោតមានភាពត្រឹមត្រូវ ។

គណៈកម្មការរៀបចំការបោះឆ្នោតនេះត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផលនៃការបោះឆ្នោត ជូនក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញប្រកាស ដើម្បីទទួលស្គាល់បេក្ខជនជាប់ឆ្នោត ។

**មាត្រា ៨៣.-**

អ្នកដែលមានសិទ្ធិបោះឆ្នោតគឺសមាជិកសភាពាណិជ្ជកម្មនិងអតីតទីប្រឹក្សាពាណិជ្ជកម្ម ។

**មាត្រា ៨៤.-**

អ្នកដែលមានសិទ្ធិឈរឈ្មោះបោះឆ្នោត គឺពាណិជ្ជករដែលមានអាយុយ៉ាងតិចបំផុតត្រឹម ៣៥ ឆ្នាំដែលមាន ចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចាប់ពី ២ ឆ្នាំយ៉ាងតិច ហើយមិនដែលមានទោសព្រហ្មទណ្ឌពីបទឧក្រិដ្ឋ ឬមជ្ឈិម ឬមិនដែលជាកម្មវត្ថុនៃនីតិវិធីស្ដារ ឬនីតិវិធីជម្រះបញ្ជីតាមផ្លូវតុលាការទេ ។

ចំពោះថេរវេលានៃការចុះបញ្ជីក្នុងបញ្ជីពាណិជ្ជកម្មយ៉ាងតិច ២ឆ្នាំ ដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនត្រូវយកមកអនុវត្តចំពោះការបោះឆ្នោតលើកដំបូងឡើយ ។

**មាត្រា ៨៥.-**

ទីប្រឹក្សាពាណិជ្ជកម្មមិនអាចធ្វើជាសមាជិកនៃសភាជម្រះក្ដីណាមួយផ្សេងទៀតបានឡើយ។

**មាត្រា ៨៦.-**

ចំនួនអាសនៈដែលត្រូវមានក្នុងពេលបោះឆ្នោតនីមួយៗ គឺមាន ៥ សំរាប់ទីប្រឹក្សាពាណិជ្ជកម្មពេញសិទ្ធិ និង ៥ សំរាប់ទីប្រឹក្សាពាណិជ្ជកម្មបំរុង ។

**មាត្រា ៨៧.-**

ការជ្រើសតាំងប្រព្រឹត្តទៅតាមការបោះឆ្នោតឯកត្តនាម ធ្វើឡើងតែមួយលើក ។

អ្នកបោះឆ្នោតម្នាក់ៗមានសម្លេងតែមួយគត់ ។ សិទ្ធិបោះឆ្នោតអាចប្រើប្រាស់បានតាមការប្រគល់សិទ្ធិ ឬ តាមសំបុត្រនៅក្នុងល័ក្ខខ័ណ្ឌដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨៨.-**

បេក្ខជន ០៥ រូប ដែលទទួលបានសម្លេងភាគច្រើនជាងគេ ត្រូវបានប្រកាសថាជាប់ឆ្នោតជាទីប្រឹក្សាពាណិជ្ជកម្មពេញសិទ្ធិ ។

បេក្ខជន ០៥ រូប ទៀតដែលទទួលបានសម្លេងភាគច្រើនបន្ទាប់ ត្រូវបានប្រកាសថាជាប់ឆ្នោតជាទីប្រឹក្សាពាណិជ្ជកម្មបម្រុង ។

ក្នុងករណីដែលមានសំលេងស្មើគ្នា បេក្ខជនដែលមានអាយុច្រើនជាងគេត្រូវបានប្រកាសថាជាប់ឆ្នោត ។

**មាត្រា ៨៩.-**

ការបោះឆ្នោតជ្រើសតាំងត្រូវប្រព្រឹត្តទៅពីរឆ្នាំម្តង ។

ក្នុងករណីដែលទីប្រឹក្សាពាណិជ្ជកម្មពេញសិទ្ធិ លែងមានលទ្ធភាពបំពេញមុខងារបានតទៅទៀត ទីប្រឹក្សាពាណិជ្ជកម្មនេះត្រូវជំនួសដោយទីប្រឹក្សាបំរុងដែលទទួលសំលេងឆ្នោតច្រើនជាងគេ សំរាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិ ។ ប៉ុន្តែ បើក្នុងរយៈពេលនេះពុំមានទីប្រឹក្សាបំរុងគ្រប់គ្រាន់ សំរាប់ជំនួសទីប្រឹក្សាពេញសិទ្ធិទេនោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចឱ្យធ្វើការបោះឆ្នោតបំពេញបានសំរាប់រយៈពេលដែលនៅសល់នៅក្នុងអាណត្តិ ។

ក្នុងករណីដែលទីប្រឹក្សាពាណិជ្ជកម្មពេញសិទ្ធិមានធុរៈបណ្តោះអាសន្ន លំដាប់សំរាប់ជំនួសទីប្រឹក្សានេះត្រូវអនុវត្តតាមដីកាសម្រេចប្រចាំឆ្នាំ របស់ប្រធានសាលាដំបូង ។

**មាត្រា ៩០.-**

វិវាទកម្មស្តីពីការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត និងដំណើរការបោះឆ្នោតជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។

## ជំពូកទី ៣
## ទណ្ឌកម្មវិន័យ

**មាត្រា ៩១.-**

ទីប្រឹក្សាពាណិជ្ជកម្មអាចត្រូវទទួលទណ្ឌកម្មវិន័យនៅក្នុងករណីមានកំហុសវិន័យ ។

ទណ្ឌកម្មវិន័យមាន ៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរមុខងារ និង
- ការដកហូតពីមុខងារ ។

គ្រប់ការបំពានដោយទីប្រឹក្សាពាណិជ្ជកម្ម ទៅលើកិត្តិយស សេចក្តីទៀងត្រង់ សេចក្តីថ្លៃថ្នូរ និងករណីយកិច្ចរបស់ខ្លួន គឺជាកំហុសវិន័យ ។

**មាត្រា ៩២.-**

ការដាក់ទណ្ឌកម្មវិន័យត្រូវធ្វើឡើង ដោយគណៈកម្មការវិន័យដែលមានក្រឡាបញ្ជីមួយរូបជាលេខាធិការ ។

គណៈកម្មការនេះមានសមាសភាព ៖

- តំណាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ០១ រូប ជាប្រធាន
- តំណាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ០១ រូប ជាសមាជិក
- តំណាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប ជាសមាជិក
- តំណាងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ០១ រូប ជាសមាជិក
- ទីប្រឹក្សាពាណិជ្ជកម្ម ០១ រូប ជាសមាជិក ។

**មាត្រា ៩៣.-**

ប្រធានសភាជម្រះក្ដីពាណិជ្ជកម្ម អាចប្ដឹងទៅគណៈកម្មការវិន័យ អំពីការបំពានទៅនឹងវិធានវិន័យ ដែលប្រព្រឹត្តដោយទីប្រឹក្សាពាណិជ្ជកម្ម ។

អង្គប្រជុំនៃគណៈកម្មការវិន័យអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកទាំងអស់ចូលរួម តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**មាត្រា ៩៤.-**

ក្រោយពីបានស្ដាប់ចម្លើយរបស់សាមីជនរួច គណៈកម្មការវិន័យធ្វើការសន្និដ្ឋាន និងវាយតំលៃ ។

ប្រសិនបើយល់ឃើញថាមានកំហុសខាងវិន័យនោះ គណៈកម្មការវិន័យសម្រេចដាក់ទណ្ឌកម្មវិន័យតាមសំលេងភាគច្រើន ។ ក្នុងករណី ដែលមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានមានឧត្តមានុភាព ។

ទណ្ឌកម្មវិន័យ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមការស្នើសុំរបស់គណៈកម្មការវិន័យ ។

**មាត្រា ៩៥.-**

ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីកំហុសខាងវិន័យធ្ងន់ធ្ងរ របស់ទីប្រឹក្សាណាម្នាក់ ប្រធានគណៈកម្មការវិន័យអាចចេញសេចក្តីសម្រេចជាបណ្តោះអាសន្ន ប្រកាសព្យួរមុខងារទីប្រឹក្សាពាណិជ្ជកម្មបានមួយរយៈពេលដែលមិនលើសពី ០៦ ខែ ។

ប្រសិនបើមានការចោទប្រកាន់ខាងព្រហ្មទណ្ឌ ទៅលើទីប្រឹក្សាពាណិជ្ជកម្មណាម្នាក់ ប្រធានគណៈកម្មការវិន័យអាចចេញសេចក្តីសម្រេចជាបណ្តោះអាសន្ន ប្រកាសព្យួរមុខងារទីប្រឹក្សានោះ រហូតដល់មានសេចក្ដីសម្រេចតុលាការជាស្ថាពរពីបទព្រហ្មទណ្ឌ ។

**មាត្រា ៩៦.-**

សេចក្ដីសម្រេចរបស់ប្រធានគណៈកម្មការវិន័យ និងសេចក្ដីសម្រេចរបស់គណៈកម្មការនេះត្រូវតែមានសំអាងហេតុ ។

**មាត្រា ៩៧.-**

ក្រោយការបោះឆ្នោត ប្រសិនបើទីប្រឹក្សាពាណិជ្ជកម្មណាម្នាក់ទទួលរងការព្រមានជាលាយលក្ខណ៍អក្សរបីដង ឬការបាត់បង់សមត្ថភាព ឬការផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ទីប្រឹក្សាពាណិជ្ជកម្មនោះ ត្រូវតែដកហូតភ្លាមជាស្វ័យប្រវត្តិពីមុខងាររបស់ខ្លួនតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## កថាភាគទី ៤
## សមត្ថកិច្ច

**មាត្រា ៩៨.-**

សភាជម្រះក្តីពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះករណីវិវាទក្នុងរឿងពាណិជ្ជកម្ម ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់សាលាដំបូង និងដែលមានតំលៃដើមលើសពី ១០ លានរៀល គឺ :

-វិវាទកម្មរវាងពាណិជ្ជករ និងពាណិជ្ជករ ស្តីពីកិច្ចសន្យា និងកិច្ចសម្រុះសម្រួលដែលមានលក្ខណៈពាណិជ្ជកម្ម ឬស្តីពីពាណិជ្ជកម្ម ។

-វិវាទកម្មរវាងសមាជិកក្រុមហ៊ុន និងសមាជិកក្រុមហ៊ុន ឬរវាងម្ចាស់ហ៊ុននៃក្រុមហ៊ុនពាណិជ្ជកម្ម ។

សភាជម្រះក្តីពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះវិវាទទាំងឡាយដែលទាក់ទងដល់ការអនុវត្តកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ។

សភាជម្រះក្តីពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះអំពីការស្តារ និងការជម្រះបញ្ជីតាមផ្លូវតុលាការរបស់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៩៩.-**

នីតិវិធីនៅមុខសភាជម្រះក្តីពាណិជ្ជកម្ម និងចិរវលាប្តឹងឧទ្ធរណ៍ ត្រូវអនុវត្តដូចគ្នានឹងបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ប្រសិនបើគ្មាននីតិវិធីពិសេសបញ្ញត្តដោយច្បាប់ ។

បណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់សភាជម្រះក្តីពាណិជ្ជកម្ម ត្រូវជំនុំជម្រះដោយសភាជម្រះក្តីពាណិជ្ជកម្ម នៃសាលាឧទ្ធរណ៍ ។

## អនុផ្នែកទី ៣
## សភាសង្គម
## កថាភាគទី ១
## ការចាត់តាំង

**មាត្រា ១០០.-**

សភាសង្គមមានសមាសភាពជាចៅក្រម និងទីប្រឹក្សាសង្គម ។

ទីប្រឹក្សាសង្គមត្រូវជ្រើសរើសដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១០២ នៃច្បាប់នេះ ។

**មាត្រា ១០១.-**

សាលក្រមរបស់សភាសង្គម ត្រូវសម្រេចដោយចៅក្រមមួយរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាសង្គមពីររូប ដែលមួយរូបជាកម្មករនិយោជិត និងមួយរូបទៀតជានិយោជក ។

**មាត្រា ១០២.-**

ទីប្រឹក្សាសង្គមមាន ០៦ រូបជានិយោជក និង ០៦ រូបទៀតជាកម្មករនិយោជិត ។ ទីប្រឹក្សាទាំងនេះត្រូវបានតែងតាំងដោយប្រកាសរួមរបស់ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមបញ្ជីឈ្មោះបេក្ខជនដែលរៀបចំឡើងដោយអង្គការវិជ្ជាជីវៈដែលមានលក្ខណៈជាតំណាងខ្ពស់ជាងគេ ។

ឈ្មោះបេក្ខជននៅក្នុងបញ្ជីនេះ ត្រូវតែមានចំនួនពីរដងនៃចំនួនមុខតំណែងដែលត្រូវតែងតាំង ។

ដើម្បីធ្វើជាទីប្រឹក្សាសង្គម បេក្ខជនទាំងពីរភេទត្រូវ :

- មានសញ្ជាតិជាខ្មែរ
- មានអាយុ ២៥ ឆ្នាំឡើងទៅ
- ពុំធ្លាប់មានទោសពីបទព្រហ្មទណ្ឌ
- មានកាយសម្បទាពេញលេញ

- មានសីលធម៌ស្អាតស្អំ
- មានកំរិតវប្បធម៌យ៉ាងតិចត្រឹមមធ្យមសិក្សាទុតិយភូមិ និង
- មានពិសោធន៍ការងារយ៉ាងតិច ៣ ឆ្នាំ ។

ទីប្រឹក្សាសង្គមមានអាណត្តិពីរឆ្នាំ និងអាចត្រូវបានតែងតាំងបានតែបីអាណត្តិប៉ុណ្ណោះ។

**មាត្រា ១០៣.-**

មុននឹងចូលកាន់តំណែង ទីប្រឹក្សាសង្គមត្រូវស្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ។

ទីប្រឹក្សាសង្គមពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាសង្គមនៃ សាលាដំបូងឡើយ ។ ទីប្រឹក្សាសង្គមត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានសភាសង្គម ។

## កថាភាគទី ២
## លក្ខន្តិកៈនៃទីប្រឹក្សាសង្គម

**មាត្រា ១០៤.-**

មុខងាររបស់ទីប្រឹក្សាសង្គមគ្មានកម្រៃទេ ។

ប៉ុន្តែ ទីប្រឹក្សាសង្គមអាចទទួលប្រាក់បំណាច់សំរាប់ការធ្វើដំណើរ ការស្នាក់អាស្រ័យនៅ និងការបាត់បង់ប្រាក់ឈ្នួល ហើយចំនួននៃប្រាក់បំណាច់នេះមិនអាចតិចជាងចំនួន នៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំនៃប្រាក់ឈ្នួលដែលបាត់បង់នោះទេ ។ ប្រាក់បំណាច់សរុបសំរាប់ខែនីមួយៗ ដែលទីប្រឹក្សាសង្គមបានបំពេញមុខងាររបស់ខ្លួននេះមិនត្រូវលើសពីប្រាក់បៀវត្ស និងប្រាក់បំណាច់ប្រចាំខែរបស់ចៅក្រមដែលមានឋានន្តរស័ក្តិទាបជាងគេនៃសភាសង្គម នៅសាលាដំបូងឡើយ ។

ចំនួនប្រាក់បំណាច់នេះនឹងត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រី នៃក្រសួងយុត្តិធម៌ ក្រសួងទទួលបន្ទុក វិស័យការងារ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១០៥.-**

ការបំពេញមុខងារជាទីប្រឹក្សាសង្គម មិនអាចជាមូលហេតុសំរាប់ឱ្យនិយោជកយកមកធ្វើការផ្តាច់កិច្ចសន្យាការងារបានឡើយ ។

ការបណ្តេញកម្មករនិយោជិតណាម្នាក់ដែលមានឈ្មោះ នៅក្នុងបញ្ជីទីប្រឹក្សាសង្គមដូចមានចែងក្នុងមាត្រា ១០២នៃច្បាប់នេះ ឬដែលបានឈប់ពីមុខងាររបស់ខ្លួនជាទីប្រឹក្សាសង្គមក្នុងរយៈពេលតិចជាង ០៦ ខែនោះ ត្រូវមានការអនុញ្ញាតពីអធិការការងារ ។

នីតិវិធីនៃការបណ្តេញចេញ ការផ្លាស់ប្តូរមុខងារ ឬការផ្ទេរការងាររបស់កម្មករនិយោជិតដែលជាទីប្រឹក្សាសង្គម ឬអតីតទីប្រឹក្សាសង្គមត្រូវអនុវត្តតាមនីតិវិធីស្តីពីការបណ្តេញចេញ ការផ្លាស់ប្តូរមុខងារ និងការផ្ទេរការងាររបស់ប្រតិភូបុគ្គលិក ដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារ ។ បទប្បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះកម្មករនិយោជិតជាបេក្ខជនសំរាប់មុខងារជាទីប្រឹក្សាសង្គមដែលមានឈ្មោះនៅក្នុងបញ្ជីស្នើឡើងដោយអង្គការវិជ្ជាជីវៈដែលមានភាពជាតំណាងខ្ពស់ជាងគេ អនុលោមតាមច្បាប់ស្តីពីការងារ។

សាមីជនទទួលបានការធានានេះ ចាប់តាំងពីពេលដាក់តម្កល់បញ្ជីបេក្ខជន។ បេក្ខជនណាដែលមិនបានជាប់ជាទីប្រឹក្សាសង្គមទេនោះ នៅតែទទួលបានការធានានេះ ជាបន្តទៅទៀតក្នុងចិរវេលា ០៣ ខែ ក្រោយពីការផ្សព្វផ្សាយបញ្ជីនៃទីប្រឹក្សាសង្គមដែលមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ។

នៅក្នុងការស៊ើបសួរអំពីពាក្យបណ្តឹង ឬអំពីឧបាស្រ័យតាមឋានានុក្រម អធិការការងារ ឬរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវពិនិត្យមើលថាតើវិធានការបណ្តេញចេញនោះ មានទំនាក់ទំនងជាមួយនឹងមុខងារជាទីប្រឹក្សាសង្គម ដែលសាមីជនប៉ងប្រាថ្នា ឬកំពុងបំពេញ ឬបានបំពេញរួចមកហើយដែរឬទេ ។

**មាត្រា ១០៦.-**

ទីប្រឹក្សាសង្គមអាចត្រូវទទួលទណ្ឌកម្មវិន័យនៅក្នុងករណីមានកំហុសវិន័យ ។

ទណ្ឌកម្មវិន័យមាន :

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរមុខងារ និង
- ការដកហូតពីមុខងារ ។

គ្រប់ការបំពានដោយទីប្រឹក្សាសង្គម ទៅលើកិត្តិយស សេចក្តីទៀងត្រង់ សេចក្តីថ្លៃថ្នូរ និងករណីយកិច្ចរបស់ខ្លួន គឺជាកំហុសវិន័យ ។

**មាត្រា ១០៧.-**

ការដាក់ទណ្ឌកម្មវិន័យ ត្រូវធ្វើឡើងដោយគណៈកម្មការវិន័យដែលមានក្រឡាបញ្ជីមួយរូបជាលេខាធិការ ។

គណៈកម្មការនេះមានសមាសភាព :

- តំណាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ០១ រូប ជាប្រធាន
- តំណាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ០១ រូប ជាសមាជិក
- តំណាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ០១ រូបជាសមាជិក
- ទីប្រឹក្សាសង្គមខាងនិយោជក ០១ រូប ជាសមាជិក
- ទីប្រឹក្សាសង្គមខាងកម្មករនិយោជិត ០១ រូប ជាសមាជិក ។

**មាត្រា ១០៨.-**

ប្រធានសភាសង្គមអាចប្តឹងទៅគណៈកម្មការវិន័យ អំពីការបំពានទៅនឹងវិធានវិន័យដែលប្រព្រឹត្តដោយទីប្រឹក្សាសង្គម ។

អង្គប្រជុំនៃគណៈកម្មការវិន័យអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកទាំងអស់ចូលរួម តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**មាត្រា ១០៩.-**

ក្រោយពីបានស្តាប់ចម្លើយរបស់សាមីជនរួច គណៈកម្មការវិន័យធ្វើការសន្និដ្ឋាន និងវាយតំលៃ ។

ប្រសិនបើយល់ឃើញថាមានកំហុសខាងវិន័យនោះ គណៈកម្មការវិន័យសម្រេចដាក់ទណ្ឌកម្មវិន័យតាមសំលេងភាគច្រើន ។ ក្នុងករណីដែលមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានមានឧត្តមានុភាព ។

ទណ្ឌកម្មវិន័យ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមការស្នើសុំរបស់គណៈកម្មការវិន័យ ។

**មាត្រា ១១០.-**

ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីកំហុសខាងវិន័យធ្ងន់ធ្ងរ របស់ទីប្រឹក្សាសង្គមណាម្នាក់ ប្រធានគណៈកម្មការវិន័យអាចចេញសេចក្តីសម្រេចជាបណ្តោះអាសន្នប្រកាសព្យួរមុខងារទីប្រឹក្សាសង្គមនោះ បានមួយរយៈពេលដែលមិនលើសពី ០៦ខែ ។

ប្រសិនបើមានការចោទប្រកាន់ខាងព្រហ្មទណ្ឌ ទៅលើទីប្រឹក្សាសង្គមណាម្នាក់ ប្រធានគណៈកម្មការវិន័យ អាចចេញសេចក្តីសម្រេចជាបណ្តោះអាសន្នប្រកាសព្យួរមុខងារទីប្រឹក្សានោះរហូតដល់មានសេចក្តីសម្រេចតុលាការជាស្ថាពរពីបទព្រហ្មទណ្ឌ ។

**មាត្រា ១១១.-**

សេចក្តីសម្រេចរបស់ប្រធានគណៈកម្មការវិន័យ និងសេចក្តីសម្រេចរបស់គណៈកម្មការនេះត្រូវតែមានសំអាងហេតុ ។

**មាត្រា ១១២.-**

ក្រោយពីត្រូវបានតែងតាំង ប្រសិនបើទីប្រឹក្សាសង្គមណាម្នាក់ទទួលរងការព្រមានជាលាយលក្ខណ៍អក្សរបីដង ឬការបាត់បង់សមត្ថភាព ឬការផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ទីប្រឹក្សាសង្គមនោះត្រូវតែដកហូតភ្លាមជាស្វ័យប្រវត្តិពីមុខងាររបស់ខ្លួន តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## កថាខណ្ឌទី ៣
## សមត្ថកិច្ច និងនីតិវិធី

**មាត្រា ១១៣.-**

សភាសង្គមនៃសាលាដំបូង មានសមត្ថកិច្ចដោះស្រាយរឿងក្តីពាក់ព័ន្ធនីតិការងារ និងបទប្បញ្ញត្តិស្តីពីរបបសន្តិសុខសង្គម នៅក្នុងដែនដីរបស់សាលាដំបូង ។

សភាសង្គមមានសមត្ថកិច្ចដូចតទៅ :

-ជំនុំជម្រះវិវាទបុគ្គល នៃការងារ ដែលកើតមានឡើងរវាង និយោជក និងកម្មករនិយោជិត ឬកូនជាងម្នាក់ ឬច្រើននាក់ តាមរឿងរៀងៗខ្លួនដែលទាក់ទងនឹងការបកស្រាយ

ឬការអនុវត្តកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ឬអនុសញ្ញារួម ឬបទប្បញ្ញត្តិច្បាប់ជាធរមាន ។

- ជំនុំជម្រះវិវាទរួមនៃការងារដែលកើតមានឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ និងបុគ្គលិករបស់ខ្លួនមួយចំនួនទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិរបស់អង្គការវិជ្ជាជីវៈ ការទទួលស្គាល់អង្គការវិជ្ជាជីវៈ ក្នុងសហគ្រាស ដែលវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម ។

-សម្រេចអំពីនីត្យានុកូលភាពនៃក្ជកម្ម ។

-ដោះស្រាយវិវាទដែលកើតចេញពីការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ទាក់ទងនឹងសិទ្ធិសហជីព ។

-ជំនុំជម្រះវិវាទស្តីអំពីសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និងភាពត្រឹមត្រូវនៃការបោះឆ្នោតជ្រើសតាំងប្រតិភូសហជីព ។ វិវាទនេះត្រូវជំនុំជម្រះបន្ទាន់ និងបិទផ្លូវឧទ្ធរណ៍ ។

-ជំនុំជម្រះវិវាទទាក់ទងនឹងរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

សភាសង្គមក៏អាចដោះស្រាយបណ្តឹងជំទាស់នឹងដំណោះស្រាយមជ្ឈត្តវិនិច្ឆ័យស្តីពីវិវាទការងារផងដែរ ។

**មាត្រា ១១៤.-**

សភាសង្គមដែលមានសមត្ថកិច្ចគឺសភាសង្គមនៃសាលាដំបូងនាទីកន្លែងអនុវត្តការងារ។

ប៉ុន្តែ ទោះបីមានការប្រគល់សមត្ថកិច្ចតាមកិច្ចសន្យាឱ្យទៅសភាសង្គមនៃសាលាដំបូងណាក៏ដោយ កម្មករនិយោជិតដែលមានទីលំនៅជាប្រចាំតាំងនៅទីកន្លែងផ្សេងពីទីកន្លែងធ្វើការនោះ មានសិទ្ធិប្តឹងទៅសាលាដំបូងនាទីលំនៅរបស់ខ្លួនក៏បាន ឬប្តឹងទៅសាលាដំបូងនាទីកន្លែងធ្វើការក៏បាន ។

**មាត្រា ១១៥.-**

សេចក្តីសម្រេចរបស់សភាសង្គមបើកផ្លូវឧទ្ធរណ៍ ។

បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជម្រះដោយសភាសង្គមនៃសាលាឧទ្ធរណ៍ ។

## ជំពូកទី ៥
## តុលាការយោធា

**មាត្រា ១១៦.-**

តុលាការយោធាមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

**មាត្រា ១១៧.-**

តុលាការយោធាមានសមត្ថកិច្ចជំនុំជម្រះបទល្មើសយោធា ដោយបើផ្លូវបណ្តឹងឧទ្ធរណ៍នៅចំពោះមុខសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។ បណ្តឹងសាទុក្ខត្រូវជំនុំជម្រះនៅចំពោះមុខសភាព្រហ្មទណ្ឌ នៃតុលាការកំពូល ។

**មាត្រា ១១៨.-**

វិធានស្តីពីសមត្ថកិច្ច ការចាត់តាំង និងដំណើរការនៃតុលាការយោធាត្រូវកំណត់ដោយច្បាប់ស្តីពីតុលាការយោធា ។

## ជំពូកទី ៦
## បទប្បញ្ញត្តិរួម

**មាត្រា ១១៩.-**

ចៅក្រមដែលមានធុរៈត្រូវបានជំនួស ដោយពិនិត្យអំពីកាលបរិច្ឆេទនិងលំដាប់ថ្នាក់នៃការតែងតាំងដូចតទៅ :

-ប្រធានតុលាការកំពូលត្រូវបានជំនួសដោយអនុប្រធានតុលាការកំពូល ដែលមានអតីតភាពការងារយូរជាងគេ ឬបើគ្មានអនុប្រធានទេ នោះត្រូវបានជំនួសដោយចៅក្រមដែលមានអតីតភាពការងារយូរជាងគេ ។

-ប្រធានសាលាឧទ្ធរណ៍ត្រូវបានជំនួសដោយអនុប្រធានសាលាឧទ្ធរណ៍ ដែលមានអតីតភាពការងារយូរជាងគេ ឬ បើគ្មានអនុប្រធានទេ នោះត្រូវបានជំនួសដោយចៅក្រមដែលមានអតីតភាពការងារយូរជាងគេ ។

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវបានជំនួសដោយអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ដែលមានអតីតភាពការងារយូរជាងគេ ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេនោះត្រូវបានជំនួសដោយព្រះរាជអាជ្ញាដែលមានអតីតភាពការងារយូរជាងគេ ។

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានជំនួសដោយអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ដែលមានអតីតភាពការងារយូរជាងគេ ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេនោះត្រូវបានជំនួសដោយព្រះរាជអាជ្ញាដែលមានអតីតភាពការងារយូរជាងគេ ។

-ប្រធានសាលាដំបូងត្រូវបានជំនួសដោយអនុប្រធាន ដែលមានអតីតភាពការងារយូរជាងគេ ឬបើគ្មានអនុប្រធានទេនោះ ត្រូវបានជំនួសដោយចៅក្រមដែលមានអតីតភាពការងារយូរជាងគេ ។

-ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបានជំនួស ដោយព្រះរាជអាជ្ញារងដែលមានអតីតភាពការងារយូរជាងគេ ។

- ប្រធានសភា ត្រូវជំនួសដោយចៅក្រមដែលមានអតីតភាពការងារយូរជាងគេ ។ បទប្បញ្ញត្តិនេះមានអានុភាពលើសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២០.-**

ប្តី, ប្រពន្ធ (សាខា?)ញាតិ និងញាតិពន្ធរហូតដល់ (ថ្នាក់ទី៤) ឪពុកមា ឬក្មួយមិនអាចចូលជំនុំជម្រះក្នុងរឿង តែមួយជាមួយគ្នាក្នុងឋានៈជាចៅក្រមក្តី ជាចៅក្រមអយ្យការក្តី ឬក៏ម្នាក់ជំនុំជម្រះនៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល នូវរឿងដែលម្នាក់ទៀតបានជំនុំជម្រះនៅសាលាដំបូង ឬសាលាឧទ្ធរណ៍បានឡើយបើពុំដូច្នោះទេសាលក្រម ឬ សាលដីកានោះត្រូវទុកជាមោឃៈ ។

**មាត្រា ១២១.-**

ចៅក្រមទាំងឡាយដែលមានញាតិ ឬញាតិពន្ធ រហូតដល់ឪពុកមា ឬក្មួយ (ញាតិថ្នាក់ទី៤) ធ្វើជាមេធាវីឱ្យគូភាគីណាមួយក្នុងរឿងក្តី មិនអាចចូលជំនុំជម្រះរឿងក្តីនោះនៅសាលាដំបូង ឬសាលាជាន់ខ្ពស់ណាមួយបានឡើយ បើពុំដូច្នោះទេសាលក្រម ឬសាលដីកានោះត្រូវទុកជាមោឃៈ ។

**មាត្រា ១២២.-**

ភាគីទាំងឡាយនៅក្នុងរឿងក្តី រួមទាំងអយ្យការផង អាចប្តឹងសុំមោឃកម្ម ចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយហេតុបំពានវិធានស្តីពីវិសមិតភាពដូចដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃមាត្រា ១២០ និងមាត្រា ១២១ នៃច្បាប់នេះ ។ បណ្តឹងសុំមោឃកម្មនេះ ត្រូវធ្វើឡើងនៅក្នុងរយៈពេលនៃបណ្តឹងទាស់ ឬបណ្តឹងឧបាស្រ័យ ។

**មាត្រា ១២៣.-**

សវនាការត្រូវធ្វើជាសាធារណៈ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។ ទោះក្នុងករណីណាក៏ដោយ សាលក្រមត្រូវប្រកាសជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ ត្រូវធ្វើជាសម្ងាត់ ។ សាលក្រមអាចប្រកាសដោយចៅក្រមមួយរូប ក្នុងចំណោមចៅក្រមដែលជាសមាសភាពនៃអង្គជំនុំជម្រះ ។

លើកលែងរឿងរដ្ឋប្បវេណី សាលក្រមត្រូវចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះ និងចុះហត្ថលេខាអមដោយក្រឡាបញ្ជីនៃសវនាការ ។

**មាត្រា ១២៤.-**

សេចក្តីចម្លង នៃសាលក្រម ឬសាលដីកាស្ថាពរ ដែលត្រូវយកទៅអនុវត្តដោយបង្ខំត្រូវមានរូបមន្តអនុវត្ត ដូចតទៅ :

"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលក្រម (ឬសាលដីកា) ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលក្រម (ឬសាលដីកា) នេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។"

## ជំពូកទី ៧
## ការត្រួតពិនិត្យសាលាជម្រះក្តី

**មាត្រា ១២៥.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រួតពិនិត្យលើដំណើរការផ្នែករដ្ឋបាល របស់សាលាជម្រះក្តីទាំងអស់ តាមរយៈអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ ។

សាលាជម្រះក្តីជាន់ខ្ពស់មានសមត្ថកិច្ចផ្តាច់មុខ ដើម្បីត្រួតពិនិត្យលើកិច្ចការជម្រះក្តីរបស់សាលាជម្រះក្តីជាន់ទាប ។ ការត្រួតពិនិត្យនេះប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌនៃផ្លូវតវ៉ា ។

**មាត្រា ១២៦.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចលើកសំណើទៅឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមដើម្បីធ្វើអធិការកិច្ចលើបញ្ហាណាមួយជាកំណត់ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១២៧.-**

មុខងារជំនុំជម្រះ និងមុខងារស៊ើបសួរ ត្រូវបែងចែកដាច់ពីគ្នា ។ គ្មានចៅក្រមណាម្នាក់ដែលទទួលបន្ទុកស៊ើបសួរសំណុំរឿងណាមួយ អាចចូលរួមជំនុំជម្រះសំណុំរឿងដែលខ្លួនស៊ើបសួរនោះបានឡើយ ។

**មាត្រា ១២៨.-**

នៅពេលរង់ចាំការប្រកាសឱ្យប្រើច្បាប់ស្តីពីនីតិវិធីរដ្ឋបាល នីតិវិធីពាណិជ្ជកម្ម និងនីតិវិធីសង្គម នីតិវិធីរដ្ឋប្បវេណីត្រូវអនុវត្តចំពោះរឿងក្តីដែលជំនុំជម្រះដោយសភារដ្ឋបាល សភាជម្រះក្តីពាណិជ្ជកម្ម និងសភាសង្គម នៃតុលាការគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩.-**

កាលបើសភាណាមួយ ពុំអាចបង្កើតឱ្យដំណើរការបាននៅក្នុងសាលាដំបូងណាមួយ ដោយហេតុថាពុំមានបេក្ខជនសំរាប់មុខងារជាចៅក្រម ឬកាលបើសភានោះត្រូវបានបង្កើត

ឡើងហើយ តែពុំអាចដំណើរការបាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាស ដើម្បីគូស បញ្ជាក់អំពីនត្ថិភាពនៃសភានោះ ។

ប្រសិនបើពុំមានសភាជម្រះក្តីពាណិជ្ជកម្ម សភារដ្ឋបាល ឬសភាសង្គម នៅក្នុង សាលាដំបូងណាមួយ ឬសភាទាំងនោះដែលបង្កើតឡើងហើយ តែពុំទាន់អាចដំណើរការបាន ទេនោះ សំណុំរឿងវិវាទក្នុងរឿងរដ្ឋបាល រឿងពាណិជ្ជកម្ម ឬរឿងសង្គម ត្រូវបញ្ជូនទៅ សភារដ្ឋប្បវេណី នៃសាលាដំបូង ។

ផ្ទុយទៅវិញ កាលណាមានបទប្បញ្ញត្តិថ្មី កំណត់អំពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ឬសភាឯកទេសណាមួយរួចហើយ តុលាការ ឬសភាឯកទេសផ្សេងទៀតត្រូវផ្ទេរជាស្វ័យប្រវត្តិ នូវសំណុំរឿងដែលមិនទាន់ចាត់ការជូនទៅតុលាការឬសភាឯកទេសដែលមានសមត្ថកិច្ចនោះ។

នៅក្នុងដំណាក់កាលដែលកម្ពុជាពុំទាន់មានចៅក្រមគ្រប់គ្រាន់ សំរាប់បង្កើតសភាទាំង អស់នៅក្នុងតុលាការ គ្រប់ជាន់ថ្នាក់ តាមចំនួនកំណត់ចាំបាច់សំរាប់សភានីមួយៗនៅឡើយទេ ចៅក្រមម្នាក់អាចធ្វើជាសមាជិកនៃសភាច្រើនបាន ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ១៣០.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣១.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។